- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជននៅក្នុង និង ក្រៅប្រទេស ចំនួន០៧រូប ដែលបានបរិច្ចាគថវិកា ចូលរួមជួយកសាង ព្រះវិហារ សាលាឆាន់ និង សមិទ្ធផលជាច្រើនទៀត នៅវត្តពុទ្ធសីម វិក្រមពោធិញាណកុមុទ ភូមិកុមុទ ឃុំគោកពូនេ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :

ក. មេដាយមាសស្ថាបនាជាតិ :

១ ឧបាសក	**ទឹម ចាន់នាង**	នៅស្រុកអូរជ្រៅ	ថវិកា ចំនួន ១០.០០០ ដុល្លារ
២-ឧបាសិកា	**សៀក ទឹម**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១០.០០០ ដុល្លារ

ខ. មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	**ស៊ឹម សមចិត្រ**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៥.០០០ ដុល្លារ
២-លោក ស្រី	**មុំ ស៊ឹម**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៥.០០០ ដុល្លារ
៣-លោក	**ចុក ចន្ទសារ**	នៅភ្នំពេញ	ថវិកា ចំនួន ៥.០០០ ដុល្លារ

គ. មេដាយសំរិទ្ធស្ថាបនាជាតិ :

១ ឧបាសក	**ម៉ក់ សំ**	នៅស្រុកអូរជ្រៅ	ថវិកា ចំនួន ១.០០០ ដុល្លារ
២-ឧបាសក	**សុខ ម៉ុនចាន់**	នៅស្រុកអូរជ្រៅ	ថវិកា ចំនួន ១.០០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៤រូប ដែលបានជួយឧបត្ថម្ភថវិកា ប្រចាំឆ្នាំ និង ឧបត្ថម្ភសម្ភារៈកីឡា រួមមាន ខោ អាវ ស្បែកជើង ស្រោមជើង ចំនួន ៣ ០០០កំប្លេ និង បាល់ទាត់ចំនួន ៥០០ ជូនសមាគមក្រុមបាល់ទាត់ យុវជនកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១ *Mr. Byun Woo Ryang ,*	ប្រធាន *Ruy Tech Co.Ltd.*
២-*Dr. D. K . Kim*	ប្រធាន *CBO Investment Group*
៣ *Mr. Soo Ho Lee*	ប្រធាន *CBO Investment Group*
៤ -*Mr. Phoung Bopha Saradeth*	ប្រធាន *CBO Investment Group*

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៣ ខែ ៥ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរិទ្ធ** ជូនមន្ត្រីចំនួន ០២ រូប ដែលមានស្នាដៃល្អ បានចូលរួមការងារក្នុងក្រុមប្រឹក្សាត់រោងចក្រអ ល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា (*ILO*) ដូចមានរាយនាមខាងក្រោម :-

១-លោក	**ម៉ក់ ពេជ្ររង្សី**	ប្រធាននាយកដ្ឋាន GSP នៃក្រសួងពាណិជ្ជកម្ម
២-លោក	**សាត សមុទ្រ**	ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

B 38

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់គ្រឿងឥស្សរិយយសការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

សម្រេច

មាត្រា១: ត្រូវបានចំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនទីប្រឹក្សា និង មន្ត្រី នៃក្រុមប្រឹក្សាគំរោង កែលំអលក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា (*ILO*) ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោមៈ-

ក.មេដាយមាសការងារ :

១-លោក *HUGO VAN NOORD*	ប្រធានទីប្រឹក្សាបច្ចេកទេស
២-លោក **ឈើម ទេយ្យារិទ្ធ**	ជំនួយការ ប្រធានទីប្រឹក្សាបច្ចេកទេស

ខ.មេដាយប្រាក់ការងារ :

កញ្ញា **សុខជា គណិកា**	ជំនួយការ ប្រធានទីប្រឹក្សាបច្ចេកទេស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា ១ និង មាត្រា ២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ នស រកម ១១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា

បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

យោងតាមសំណើរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

ស ម្រេ ច

មាត្រា ១ : ត្រូវបានចាត់មន្ត្រីរាជការ នៃរាជបណ្ឌិត្យសភាកម្ពុជាចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម អោយបំពេញមុខងារដូចតទៅ :

- លោកស្រីបណ្ឌិត **សៀង ស៊ុយ** ជា**ប្រធានផ្នែកគីមីវិទ្យានិងចំណីអាហារ** នៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានឋានៈស្មើ**ប្រធាននាយកដ្ឋាន**។
- លោក **ជួ គរី** ជា**ប្រធានផ្នែកខេមរនីយកម្ម វចនានុក្រមនិងបកប្រែ** នៃវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើ**ប្រធាននាយកដ្ឋាន**។

៣. លោក **យស់ ចំនួនតារា** ជាប្រធានផ្នែកពាណិជ្ជសាស្ត្រនិងការគ្រប់គ្រងនៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានឋានៈស្មើប្រធាន**នាយកដ្ឋាន**។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយសុវត្ថារា

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានអគ្គនាយកកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជាកិច្ចបច្ចាមរណៈ ជូនសពលោក **ចិ ហេមចន្ទ** ប្រធានការិយាល័យកណ្តាល នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង ប្រធានអគ្គនាយកកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ [illegible]

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០៤/០១៧ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **សេង សុខុម** ជាជំនួយការឯកឧត្តម **ជា ចំរើន** ទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១ សសរ

សេចក្តីសំរេច

ស្តីពីការបង្កើតគណៈកម្មការរៀបចំ

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកុមារក្នុង

តំបន់អាស៊ីប៉ាស៊ីហ្វិក នាថ្ងៃទី ២៣-២៥ ខែមីនា ឆ្នាំ ២០០៥ នៅខេត្តសៀមរាប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤
  ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស
  អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
  បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង
  ការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
  យោងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៦ ស្តីពីកុមារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ថ្ងៃទី ៥-៧
  ខែ ឧសភា ឆ្នាំ ២០០៣ នៅបាលី ប្រទេសឥណ្ឌូនេស៊ី
- យោងលិខិតរបស់អង្គការ UNICEF ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣
- យោងលិខិតរបស់ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ លេខ ១៤៤៣ អជ.កបទ.សអ ចុះ
  ថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០០៣
- យោងតំរូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១: ត្រូវបានបង្កើតគណៈកម្មការ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកុមារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នៅខេត្តសៀមរាប ថ្ងៃទី ២៣-២៥ ខែមីនា ឆ្នាំ ២០០៥ ដែលមានសមាសភាព ដូចខាងក្រោម:

១. ឯកឧត្តម **អ៊ិត សំហេង**	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	ប្រធាន
២.ឯកឧត្តម **ខៀវ ខុន**	រដ្ឋលេខាធិការ ក្រសួងទេសចរណ៍	អនុប្រធាន
៣. ឯកឧត្តម **ឡុង វិសាលោ**	រដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៤ ឯកឧត្តម **ភ្លី សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៥ ឯកឧត្តម **នឹម ថុត**	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	អនុប្រធាន
៦ ឯកឧត្តម **អ៊ុំ នាស៊ាង**	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	សមាជិក
៧.ឯកឧត្តម **យឹម សារិទ្ធ**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៨.ឯកឧត្តម **អ៊ុំ ម៉ុនឡុង**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៩ ឯកឧត្តម **អ៊ឹម សិទ្ធី**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១០. ឯកឧត្តម **ម៉ម ប៊ុនហេង**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
១១. ឯកឧត្តម **អ៊ី ដន**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
១២. លោកជំទាវ **យូ អយ**	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	សមាជិក
១៣.ឯកឧត្តម **សេង លឹមនៅ**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៤.ឯកឧត្តម **កែវ សាវឿន**	អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
១៥ ឯកឧត្តម **ជា សុខុម**	អគ្គលេខាធិការរងទី១នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ	សមាជិក
១៦ ឯកឧត្តម **ស៊ឹម សុន**	អភិបាលខេត្តសៀមរាប	សមាជិក
១៧.ឯកឧត្តម ឧត្តមសេនីយ៍ត្រី **នួន ម៉ុជល** ស្នងការនគរបាលខេត្តសៀមរាប		សមាជិក
១៨. ឯកឧត្តម **កែវ បូរស្មី**	អគ្គនាយកសង្គមកិច្ច ក្រសួង ស.អ.យ	សមាជិក
១៩. លោក **ឃួន វ៉ាន់ឌីន**	អគ្គនាយករងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួង ស.អ.យ	សមាជិក
២០. លោកស្រី **ចំនួ ហាវ៉ាន់ថង្ងី**	អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ	សមាជិក

ប្រការ ២: គណៈកម្មការនេះមានការកិច្ចសហការជាមួយអង្គការយូនីសេហ្វដើម្បីសម្របសម្រួល ដឹកនាំការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់។

ប្រការ ៣: គណៈកម្មការ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អាចបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ដើម្បីជួយសម្រួលដល់ការងាររបស់ខ្លួន។

ប្រការ ៤: សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

ប្រការ ៥: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ដល់ថវិកាជាបន្ទុកថវិកាជាតិកម្ពុជាសំរាប់កិច្ចប្រជុំនេះ។

ប្រការ ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

ដូចប្រការ ៦

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩២ . សសរ

សេចក្តីសម្រេច

ស្តីពីការបង្កើតគណៈកម្មការចំរុះ
សំរាប់សិក្សា និងវាយតំលៃលើគំរោងវិនិយោគស្ពាន និងអគ្គិសនី
រមណីយដ្ឋានតំបន់ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក់ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយតាព្រហ្ម ប្រាសាទឯកភ្នំ និងប្រាសាទភ្នំបាណន់ សំរាប់បំរើសំណូមពរវិនិយោគ
របស់ក្រុមហ៊ុន SOKHA HOTEL CO., LTD.

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ និងលេខ៣៩ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤

យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១

- យោងសេចក្តីសម្រេចលេខ១៣ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២ និងសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

ប្រការ១: ចាត់ទុកជាមោឃៈនូវសេចក្តីសម្រេចលេខ១៣ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២ និងសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០២។

ប្រការ២: បង្កើតគណៈកម្មការថ្មី ដើម្បីទទួលការងារពីគណៈកម្មការដែលបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ១៣ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២ និងសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០២ ក្នុងការសិក្សា និងវាយតម្លៃលើគម្រោងវិនិយោគស្តារ និងអភិវឌ្ឍន៍រមណីយដ្ឋានតំបន់ប្រាសាទព្រះវិហារ ក្នុងខេត្តព្រះវិហារ ប្រាសាទសំបូរព្រៃគុក ក្នុងខេត្តកំពង់ធំ-ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព ក្នុងខេត្តបន្ទាយមានជ័យ និងប្រាសាទឯកភ្នំ ប្រាសាទភ្នំបាណន់ ក្នុងខេត្តបាត់ដំបង សំរាប់បំពេញគម្រោងវិនិយោគរបស់ក្រុមហ៊ុន SOKHA HOTEL CO., LTD ដោយមានសមាសភាព ដូចខាងក្រោម៖

១- ឯកឧត្តម **នុត ណារ៉ុង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
២ ឯកឧត្តម **សុខ ចិន្ដា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣ ឯកឧត្តម **ជុច ភឿន** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធាន
៤- ឯកឧត្តម **តាវ គឹមហុង** ប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជា-ថៃ អនុប្រធាន
៥ ឯកឧត្តម **សេខ លីមនៅ** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
៦ ឯកឧត្តម **ខ្លាញ់ ស៊ុន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
៧ ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា សមាជិក
៨- ឯកឧត្តម **រស់ រ៉េន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
៩ ឯកឧត្តម **ស្រុន តារា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១០ ឯកឧត្តម **នូ ភឿខ** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក
១១ ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក
១២ ឯកឧត្តម **ឌិត ហែន** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក
១៣- ឯកឧត្តម អភិបាលខេត្តព្រះវិហារ សមាជិក
១៤ ឯកឧត្តម អភិបាលខេត្តកំពង់ធំ សមាជិក
១៥- ឯកឧត្តម អភិបាលខេត្តបាត់ដំបង សមាជិក
១៦ ឯកឧត្តម អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
១៧ លោក **មុខ ម៉ិនហួន** ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខាធិការ

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

ប្រការ៣: គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

ក. ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែងនូវបញ្ហាចំពោះមុខបច្ចុប្បន្ន អំពីផលដែលអាចនាំអោយមានការប្រែប្រួលបរិស្ថាន នៅតំបន់ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព - ប្រាសាទភ្នំបាណន់ និងប្រាសាទឯកភ្នំ ។

ខ. សិក្សា និងវាយតំលៃលើទិដ្ឋភាពច្បាប់ បច្ចេកទេសពាក់ព័ន្ធដល់គំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋានដូចមានចែងក្នុងប្រការ២ ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យសំរេចក្នុងអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" លើសំណើសុំវិនិយោគរបស់ក្រុមហ៊ុន SOKHA HOTEL CO,LTD នេះ ។

ក្នុងករណីសំណើសុំវិនិយោគរបស់ក្រុមហ៊ុននេះ ត្រូវបានអនុញ្ញាតអោយវិនិយោគដោយមានការលើកទឹកចិត្តនោះ គណៈកម្មការនេះត្រូវមានភារកិច្ចបន្ត ដូចខាងក្រោម :

- រៀបចំរៃ បបទ ឯកសារគតិយុត្តិ កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំងនេះ អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក ។
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមដំណាក់កាលនីមួយៗ ។
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។
- លើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល តាមរយៈយន្តការ "ច្រកចេញ ចូលតែមួយ" របស់ [illegible]

ប្រការ៤: គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

ប្រការ៥: សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា-រដ្ឋមន្ត្រីគ្រប់ក្រសួង-គ្រប់ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
  ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៥ ណ.ស.

លិខិតបញ្ជា
ស្តីពី
វិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

កន្លងមករាជរដ្ឋាភិបាល បានចេញលិខិតបញ្ជា លេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ប៉ុន្តែ សកម្មភាពអំពើរត់គេចពន្ធនៅតាមព្រំដែន នៅច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅតែកើតមានដោយចំហ និងច្រើនរូបភាពនៅឡើយ ។

ឆ្លងតាមកិច្ចពិភាក្សា និងសំណូមពរនានា នៃអង្គសន្និសីទជាតិ ស្តីពីការពង្រឹងអភិបាលកិច្ចល្អ ដើម្បីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍ នាថ្ងៃទី ១៤-១៥ និងទី១៦ ខែ ធ្នូ ឆ្នាំ ២០០៤ និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាពិសេសក្នុងការបង្ក្រាបអំពើរត់គេចពន្ធ រាជរដ្ឋាភិបាលចេញបទបញ្ជាដូចខាងក្រោម :

១ អភិបាលខេត្ត ក្រុង ត្រូវដឹកនាំដោយផ្ទាល់លើកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ភ្នាក់ងារគយ និងរដ្ឋាករ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តលើការងារស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដែលកើតមាននៅក្នុងមូលដ្ឋាន ខេត្ត ក្រុង របស់ខ្លួន ។

២-អនុញ្ញាតអោយអភិបាលខេត្ត ក្រុង ទទួល និងបែងចែកលាភការពីការចាប់ឃាត់ទំនិញរត់គេចពន្ធនៅក្នុងដែនដីរបស់ខ្លួន គឺ ៦០% បង់ចូលថវិកាខេត្ត ក្រុង ៣០% ជារង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃក្នុងការបង្ក្រាបអំពើរត់គេចពន្ធ និង ១០% បង់ចូលបេឡាមូលនិធិ បង្ក្រាបអំពើរត់គេចពន្ធ ក្នុងមូលដ្ឋានខេត្ត ក្រុង សាមីរូបរាយការណ៍ អំពីលទ្ធផលនៃការចាប់ឃាត់ទំនិញរត់គេចពន្ធ និងថវិកា ដែលបានមកពីការលក់ទំនិញរត់គេចពន្ធស្របតាមនីតិវិធីជាធរមានទាំងនោះ មកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន ។

៣-បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីលិខិតបញ្ជានេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ទទួលបានលិខិតបញ្ជានេះ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត ក្រុង ត្រូវទទួលអនុវត្តតាមខ្លឹមសារខាងលើ អោយទទួលបានលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ... អយក.ប្រក

ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា ចុះតាផង់

ជាសាលាបឋមសិក្សាពេញលក្ខណៈ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង អប្បរំសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
- បានពិនិត្យលិខិតស្នើសុំរបស់ គណៈកម្មការសាងសង់អគារសិក្សាសាលាចុះតាផង់ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពរបស់ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពត ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៤ និងយោបល់ឯកភាពរបស់អភិបាលខេត្តកំពត ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៤
- តាមសំណើរបស់ **នាយកដ្ឋានបឋមសិក្សា**

សម្រេច

ប្រការ១ បើកសាលាបឋមសិក្សា **ចុះតាផង់** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅឃុំ **ស្នែងខែម** ស្រុក **ជុំគិរី** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ នេះតទៅ ។

ប្រការ២ : សាលាបឋមសិក្សា **ចុះតាផង់** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសម្រាប់សាលាបឋមសិក្សា ។

ប្រការ៣ នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ៤ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពត ការិយាល័យអប់រំ យុវជន និងកីឡាស្រុកជុំគិរី នាយកសាលាបឋមសិក្សា **ចុះតាផង់** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ ... ឆ្នាំ ២០០៤

ទ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម.សេធី

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត **កំពត**
- "**ដើម្បីជូនជ្រាបជាពត៌មាន**"
- ដូចប្រការ ៤ -កាលប្បវត្តិ-ឯកសារ ១ ចប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ៣១៤៥ អយក.ប្រក

ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា ត្រពាំងថ្លែល
ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ស្រែជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦ ០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៖ អនុក្រ.បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
- តាមសំណើរបស់លោក ... ក្រុមប្រឹក្សាភូមិ ... ឆ្នាំ២០០៤ ដោយមានការឯកភាពរបស់មន្ទីរអប់រំយុវជន និង កីឡាខេត្ត កំពត ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ និង ...ចុះថ្ងៃទី ... ខែ សីហា ឆ្នាំ ២០០៤
- តាមសំណើរបស់ នាយកដ្ឋានបឋមសិក្សា

សម្រេច

ប្រការ១ . បើកសាលាបឋមសិក្សា **ត្រពាំងថ្លើល** ជាឧបសម្ព័ន្ធរបស់ សាលាបឋមសិក្សា **ស្រែជា** ដែលមានទីតាំងស្ថិតនៅភូមិ ច្រើតីរ ឃុំ **ស្រែជាខាងជើង** ស្រុក **ជ័យសែន** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ នេះតទៅ ។

ប្រការ២ . សាលាបឋមសិក្សា **ត្រពាំងថ្លើល** ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **ស្រែជា** ។

ប្រការ៣ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ជ័យសែន** នាយកសាលាបឋមសិក្សា **ស្រែជា** និង ប្រធានក្រុមសាលា ឧបសម្ព័ន្ធ **ត្រពាំងថ្លើល** មានភារកិច្ចអនុវត្តប្រកាសនេះ ។

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត កំពត
- "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣ កាលប្បវត្តិ ឯកសារ និង បស

ភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៤
ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១៥៦៤ អយក.ប្រក

ប្រកាស

ស្តីពី ការប្តូរឈ្មោះសាលាបឋមសិក្សា ស្ទឹងសាមគ្គី មកជាសាលាបឋមសិក្សា សៀវគុយទៀវមុយ ស្ទឹងសាមគ្គី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលឈ្មោះនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
- បានពិនិត្យលិខិតស្នើសុំរបស់នាយកសាលា និង សហគមន៍ មាតាបិតាសិស្សនៃសាលាបឋមសិក្សា ស្ទឹងសាមគ្គី ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត កំពង់ធំ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ និង យោបល់ឯកភាពរបស់អភិបាលរងទី៣ ខេត្ត កំពង់ធំ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

សម្រេច

ប្រការ១ ប្តូរឈ្មោះសាលាបឋមសិក្សា ស្ទឹងសាមគ្គី មកជា សាលាបឋមសិក្សា សៀវគុយទៀវមុយ ស្ទឹងសាមគ្គី វិញ ដែលមានទីតាំងស្ថិតនៅឃុំ ពង្រ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ នេះតទៅ ។

ប្រការ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ធំ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក បារាយណ៍ នាយកសាលាបឋមសិក្សា សៀវគុយទៀវមុយ ស្ទឹងសាមគ្គី មានភារកិច្ចអនុវត្តប្រកាសនេះ ។ na ad eng hol

ភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤
ឧ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
ប្រធានាធិការ

អ៊ឹម.សិទ្ធី

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត កំពង់ធំ
- "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៣ -កាលប្បវត្តិ-ឯកសារ ខា បស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ: ... អយក.ប្រក

ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា ហ្គារ៉ែត ម៉ះហ្គាន កែវ មុនីវង្សាសាន ជាសាលាបឋមសិក្សាពេញលក្ខណៈ

ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បានឃើញព្រះរាជក្រឹត្យលេខនស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការ កែសំរួលឋានន្តរស័ក្តិនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

បានពិនិត្យលិខិតស្នើសុំ របស់ គណៈកម្មការទទួលបន្ទុកសាលាបឋមសិក្សា ហ្គារ៉ែត ម៉ះហ្គាន កែវ មុនីប្រាសាទ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានយោបល់ពីការិយាល័យ មន្ទីរអប់រំ យុវជន និង កីឡាខេត្ត កំពត ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៤និងយោបល់ការិយាល័យ អភិបាលខេត្ត ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៤

តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

សំរេច

ប្រការ១ បើកសាលាបឋមសិក្សា **ហ្គារ៉ែត ម៉ះហ្គាន កែវ មុនីវង្សាសាន** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅភូមិ **ឃ្លាំខ្មៅខាងជើង** ឃុំ **កំពង់ត្រាចខាងកើត** ស្រុក **កំពង់ត្រាច** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ នេះតទៅ ។

ប្រការ២ សាលាបឋមសិក្សា **ហ្គារ៉ែត ម៉ះហ្គាន កែវ មុនីវង្សាសាន** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ៣ . នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ៤ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក កំពង់ត្រាច នាយកសាលាបឋមសិក្សា **ហ្គារ៉ែត ម៉ះហ្គាន កែវ មុនីវង្សាសាន** មានភារកិច្ចអនុវត្តប្រកាសនេះ ។

កន្លែងទទួល

- រិស្វិការគណៈរដ្ឋមន្ត្រី
- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត **កំពត**
- "ដើម្បីជូនព្រាបជាពត៌មាន"
- ដូចប្រការ ៤ -កាលប្បវត្តិ-ឯកសារ នា បស

ភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

ជ. ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

ឆ្នាំទី ៤ លេខ ៤៧ ថ្ងៃ ទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៤ រាជកិច្ច ទំព័រ ២៩៨០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: [illegible] អយក.ប្រក

ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា សេរីភាព

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ខ្សូរ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលលេខទោសម្ព័ន្ធ នាយកដ្ឋានបឋម និង មធ្យមសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
- បានពិនិត្យលិខិតស្នើសុំរបស់ [illegible] និង ប្រជាពលរដ្ឋនៅភូមិសេរីភាព ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៤ ដោយមានយោបល់ [illegible] មន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៤ និង [illegible]
- តាមសំណើរបស់ នាយកដ្ឋានបឋមសិក្សា

សម្រេច

ប្រការ១ បើកសាលាបឋមសិក្សា សេរីភាពជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ខ្សូរ ដែលមានទីតាំងស្ថិតនៅភូមិ សេរីភាព ឃុំ ជារ ស្រុក ក្រចេះ ខេត្ត ក្រចេះ ចាប់ពីឆ្នាំសិក្សា ២០០៤ ២០០៥ នេះតទៅ ។

ប្រការ២ សាលាបឋមសិក្សាសេរីភាព ត្រូវដឹកនាំដោយ ប្រធានក្រុមមួយរូប ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា ខ្សូរ ។

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ក្រចេះ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រចេះ នាយកសាលាបឋមសិក្សា ខ្សូរ និង ប្រធានក្រុមសាលាបឋមសិក្សា សេរីភាព ត្រូវអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៤

ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សេធី

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត ក្រចេះ
- "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣
- កាលប្បវត្តិ ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១៦៩៨ អយក ប្រក

ប្រកាស
ស្តីពី ការបើកសាលាបឋមសិក្សា វិជ្ជាលស្នើ
ជាសាលាបឋមសិក្សាពេញលក្ខណៈ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

បានឃើញអនុក្រឹត្យលេខ២១ អនក្រ បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលភារកិច្ចនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

បានពិនិត្យលិខិតស្នើសុំ របស់ គណៈកម្មការទ្រទ្រង់ សាលាបឋមសិក្សា វិជ្ជាលស្នើ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសំណើសុំបើកសាលាបឋមសិក្សា វិជ្ជាលស្នើ របស់ប្រធានមន្ទីរ អប់រំយុវជន និង កីឡា ខេត្ត តាកែវ ចុះថ្ងៃទី២៧ខែ កក្កដា ឆ្នាំ ២០០៤

តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

សម្រេច

ប្រការ១ ។ បើកសាលាបឋមសិក្សា វិជ្ជាលស្នើ ជាសាលាបឋមសិក្សាពេញលក្ខណៈ សិក្សាថ្នាក់ទី ១ ដល់ ទី ៦ ដែលមានទីតាំងស្ថិតនៅភូមិ **អូរត្រុះជួរ** ឃុំ **អង្គកែវ** ស្រុក **ទ្រាំង** ខេត្ត **តាកែវ** ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ នេះតទៅ ។

ប្រការ២ ។ សាលាបឋមសិក្សា វិជ្ជាលស្នើ ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋាន ឬ ក្របខ័ណ្ឌសម្រាប់សាលាបឋមសិក្សា ។

ប្រការ៣ ។ នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ៤ ។ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ទ្រាំង** នាយកសាលាបឋមសិក្សា វិជ្ជាលស្នើ មានភារកិច្ចអនុវត្តប្រកាសនេះ ។

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត **តាកែវ**
- "**ដើម្បីចុះផ្សាយក្នុងរាជកិច្ច**"
- ដូចប្រការ ៤
- កាលប្បវត្តិ ឯកសារ នា បស

ភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៤

ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៧[illegible] អយក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ តាអុង

ស្ថិតនៅក្នុងឃុំគោកល្វៀង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

—

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/[illegible]/១១៩៦/៥២ ចុះថ្ងៃទី ០៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធ[illegible] ១០ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ០[illegible] ខែ [illegible] ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញ[illegible] ស្តីពី[illegible] ស្រុកមង្គលបូរី ចុះថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៤ [illegible] នៃ[illegible] អប់រំ យុវជន និងកីឡា [illegible]
- [illegible]

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យ មួយដែលមានឈ្មោះថា អនុវិទ្យាល័យ " តាអុង " ស្ថិតនៅក្នុងឃុំគោកល្វៀង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០៤ ២០០៥ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របទៅនឹងចំនួនសិស្សតាមអត្រាពេញនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់តាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងនាយកអនុវិទ្យាល័យខាងលើ មានភារកិច្ចអនុវត្តប្រកាសនេះ ។

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
  ខុទ្ទកាល័យនាយករដ្ឋមន្ត្រីខាងសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  ដើម្បីជ្រាបជាពត៌មាន
- សាលាខេត្តបន្ទាយមានជ័យ ដើម្បីជាពត៌មាន
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

ថ្ងៃទី ០១ ខែ ៥ ឆ្នាំ ២០០៤

បណ្ឌិត គឹម សួរ ភិរិទ្ធ

New School\New NewAnk

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ១០៣៧ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ហោល

ស្ថិតនៅក្នុងឃុំហោល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម [illegible] ១៩៩៦ ចុះថ្ងៃទី [illegible] ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ [illegible] ០៧៩៦ ៥២ ចុះថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ [illegible] អនក្រ.បក ចុះថ្ងៃទី [illegible] ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលើលិខិតលេខ ៦៦ [illegible] ចុះថ្ងៃទី [illegible] ស្តីពីសំណើសុំបើកសាលាមធ្យមសិក្សាកម្រិតទី១ [illegible] ស្រុកព្រះនេត្រព្រះ [illegible] ១៧ [illegible] ឆ្នាំ [illegible] មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ
- [illegible]

សម្រេច

ប្រការ ១ ៖ អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា អនុវិទ្យាល័យ [illegible] ស្ថិតនៅក្នុងឃុំហោល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ តទៅ ។

ប្រការ ២ ៖ អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកបង្រៀន មួយចំនួនទៀតតាមអត្រាការងារនៃអនុវិទ្យាល័យ ។

ប្រការ ៣ ៖ នាយក នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ ៖ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

បណ្ឌិត កុល ផេង

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  ដើម្បីជ្រាបជាព័ត៌មាន
- សាលាខេត្តបន្ទាយមានជ័យ ដើម្បីជាព័ត៌មាន
- ដូចប្រការ ៤
- កាលប្បវត្តិ ឯកសារ [illegible]

New school\Lower New.doc

ព្រះរាជាណាចក្រកម្ពុជា
